Ratanak International

# សេចក្តីប្រកាសការងារ
# អង្គការរតនៈអន្តរជាតិ
## ខែមិថុនា ឆ្នាំ២០១៤

អង្គការរតនៈអន្តរជាតិ គឺជាអង្គការសប្បុរសធម៌គ្រីស្ទបរិស័ទ ដែលបានចាប់ផ្តើមក្នុងឆ្នាំ ១៩៨៩ នៅក្នុងប្រទេសកម្ពុជា។ អង្គការរតនៈកំពុងស្វែងរកគ្រីស្ទបរិស័ទចាស់ទុំ និងបេក្ខជន ដែលមានបទពិសោធន៍ ដើម្បីបម្រើការងារទៅតាមតួនាទីដូចខាងក្រោមនេះ សម្រាប់ផ្ទះសហគមន៍នៃកម្មវិធី RAP និងនៅការិយាល័យប្រតិបត្តិក្នុងប្រទេសកម្ពុជា។

**1)** អ្នកសម្របសម្រួលផ្នែកបុគ្គលិកថែទាំ: ១ តំណែង

### គោលបំណង និងទំនួលខុសត្រូវនៃតំណែងនេះ

ដើម្បីផ្តល់ការអភិបាលកិច្ច, ការគ្រប់គ្រង និងត្រួតពិនិត្យចំពោះអ្នកថែទាំផ្ទះ រ៉ាប ដើម្បីធានាថាពួកគេផ្តល់ការថែទាំ ដែលមានគុណភាព និងគាំពារដល់អតិថិជន ដែលរស់នៅក្នុងផ្ទះសហគមន៍នៃកម្មវិធី RAP។ ទទួលខុសត្រូវចំពោះការគ្រប់គ្រង និងត្រួតពិនិត្យចំពោះអគារបរិក្ខានៃកម្មវិធី RAP ដើម្បីធានាឲ្យមានដំណើរការដោះស្រាយទាន់ពេលវេលាសម្រាប់ការជួសជុល, ការថែទាំ និងបញ្ហាប្រតិបត្តិការប្រចាំថ្ងៃ។ ផ្តល់ការគាំពារផ្នែកព្រលឹងវិញ្ញាណ និងការថែរក្សាដល់បុគ្គលិកថែរទាំនៅផ្ទះ រ៉ាប។

### ជំនាញនិងបទពិសោធន៍ ដែលត្រូវការ

- មានជំនាញនិយាយ និងសរសេរប្រាស្រ័យទាក់ទងជាភាសាខ្មែរ និងអង់គ្លេស
- មានចំណេះដឹងលើកម្មវិធីកុំព្យូទ័រ(Word, Excel)
- មានចំណេះដឹងក្នុងការចាត់ចែង និងផ្ទៀងផ្ទាត់សាច់ប្រាក់
- មានជំនាញទំនាក់ទំនងអន្តរបុគ្គលល្អប្រសើរ
- មានភាពចាស់ទុំ, ស្វាហាប់, ខិតខំធ្វើការងារ, មានសណ្តាប់ធ្នាប់ និងចេះរៀបចំឲ្យមានលក្ខណៈជាប្រព័ន្ធ
- មានជំនាញធ្វើការងារជាក្រុម
- មានសមត្ថភាពដោះស្រាយបញ្ហា
- មានសមត្ថភាពក្នុងការរក្សាកំណត់ត្រាបានត្រឹមត្រូវ

### ការអប់រំ និងបទពិសោធន៍ ដែលត្រូវការ

- បរិញ្ញាប័ត្រផ្នែកចិត្តវិទ្យា

Ratanak International

- មានបទពិសោធន៍ផ្នែកពិគ្រោះយោបល់កាន់តែល្អប្រសើរ
- មានបទពិសោធន៍ធ្វើការងារជាមួយផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល
- មានបទពិសោធន៍ធ្វើការងារជាមួយជនរងគ្រោះ ដែលប៉ះទង្គិចអារម្មណ៍
- មានបទពិសោធន៍យ៉ាងតិច ៤ឆ្នាំ ក្នុងការបម្រើការងារក្នុងតួនាទីគ្រប់គ្រងនៅក្នុងមណ្ឌលថែទាំ ឬក្នុងបរិយាកាសជាផ្ទះស្នាក់នៅជាក្រុម
- ជាគ្រីស្តបរិស័ទ ដែលចូលរួមក្រុមជំនុំក្នុងស្រុកយ៉ាងទៀងទាត់

បេក្ខជនទាំងអស់ ដែលមានបំណងដាក់ពាក្យ **ដំបូង**គួរតែទទួលបានសេចក្តីពិពណ៌នាការងារដែលពាក់ព័ន្ធតាមរយៈអាស័យដ្ឋានអ៊ីមែលៈnarun.chhay@ratanak.orgហើយបញ្ជាក់ពីតួនាទី ដែលចង់ដាក់នៅក្នុងប្រអប់ប្រធានបទ។ បេក្ខជន ដែលមានចំណាប់អារម្មណ៍គួរតែប្រគល់ប្រវត្តិរូបសង្ខេបរបស់ខ្លួន ដោយភ្ជាប់លិខិតចំណាប់អារម្មណ៍មកជាមួយ នៅថ្ងៃ ឬមុន **ថ្ងៃព្រហស្បត្តិ៍ ទី ២៤ ខែមិថុនា ឆ្នាំ២០១៤ ត្រឹមម៉ោង ៤ :៣០ល្ងាច ទៅកាន់ៈ អង្គការរតនៈអន្តរជាតិ (កម្ពុជា) ដែលមានអាស័យដ្ឋានៈ ផ្ទះលេខ ១៣B, ផ្លូវលេខ ៥១, ជាន់ទី ១, អគារ B, សង្កាត់បឹងកេងកង ១, ខ័ណ្ឌចំការមន, ក្រុងភ្នំពេញ ឬអ៊ីមែលមកកាន់ៈnarun.chhay@ratanak.org**

អង្គការរតនៈអន្តរជាតិ គឺជាស្ថាប័ន ដែលផ្តល់ឱកាសការងារស្មើគ្នា ដោយទទួលបានអត្រានៃអត្ថប្រយោជន៍បែបប្រកួតប្រជែង និងមានល័ក្ខខ័ណ្ឌ និងស្ថានភាពការងារល្អប្រសើរ។ ស្រ្តីត្រូវបានជម្រុញយ៉ាងខ្លាំងឲ្យដាក់ពាក្យ។ **មានតែបេក្ខជនជាប់ឈ្មោះដំបូងប៉ុណ្ណោះ នឹងត្រូវបានទាក់ទងសម្រាប់ការសម្ភាសន៍។** បុគ្គលិកទាំងអស់តម្រូវឲ្យគោរពតាមគោលនយោបាយការពារកុមារ, កិច្ចព្រមព្រៀងរក្សាភាពសម្ងាត់ និងគុណតម្លៃនៃអង្គការរតនៈអន្តរជាតិ។